# គម្លាតឌីជីថល

បញ្ហាគម្លាតឌីជីថលនៅតែបន្តកើតមានជាសកល ខណៈពេលដែលការរីកចម្រើននៃការតភ្ជាប់អ៊ីនធឺណិត និងអក្ខរកម្មឌីជីថល ពុំទាន់មានភាពគ្រប់គ្រាន់នៅឡើយ ជាពិសេសនៅក្នុងសហគមន៍ដែលងាយរងគ្រោះ តំបន់ជនបទ និងប្រទេសកំពុងអភិវឌ្ឍន៍។ យ៉ាងណាមិញ គម្លាតឌីជីថលត្រូវបានគេចាប់អារម្មណ៍កាន់តែខ្លាំងបន្ទាប់ពីការមកដល់នៃវិបត្តិជំងឺកូវីដ-១៩ ដែលបានផ្លាស់ប្តូរគ្រប់ទិដ្ឋភាពនៃជីវិតរស់នៅរបស់យើង ទាំងការងារ, ការអប់រំ និងប្រព័ន្ធបណ្តាញសង្គមផងដែរ។ ក្នុងអំឡុងពេលនោះ ការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិតនៅលើពិភពលោកមានការរីកចម្រើនយ៉ាងរហ័ស ដោយយោងតាមទិន្នន័យរបស់ ITU ក្នុងឆ្នាំ២០២០ មានមនុស្សចំនួនប្រមាណ **៤៦៦លាននាក់** បានប្រើប្រាស់អ៊ីនធឺណិត។ វិបត្តិជំងឺកូវីដ-១៩បានធ្វើឱ្យប្រទេសលើសកលលោកបង្វែរការចាប់អារម្មណ៍មកលើតួនាទីដ៏សំខាន់នៃការតភ្ជាប់ឌីជីថលសម្រាប់ការអប់រំ ការងារ ការថែទាំសុខភាព និងអន្តរកម្មសង្គម។ បន្ថែមពីនេះ ចំនួនអ្នកប្រើប្រាស់អ៊ីនធឺណិតទូទាំងសកលលោក និងភាគរយនៃការជ្រៀតចូលនៃប្រព័ន្ធអ៊ីនធឺណិតបានបន្តកើនឡើងពីឆ្នាំ២០២១ ដល់ឆ្នាំ២០២២ នៅចន្លោះ **៧%** និង **៦%** ដែលកំណើននេះបានបង្ហាញថា មានការរីកចម្រើនខ្លាំងក្នុងការចូលប្រើប្រាស់បច្ចេកវិទ្យាឌីជីថល។ ដោយឡែក ការកើនឡើងយ៉ាងលឿននៃបច្ចេកវិទ្យាឌីជីថលក៏បានបង្កឱ្យមានបញ្ហាគម្លាតឌីជីថលផងដែរ ដោយគិតត្រឹមឆ្នាំ២០២២ មនុស្សប្រមាណ **២,៧ប៊ីលាននាក់** ស្មើនឹង ១/៣ នៃពិភពលោកមិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត ហើយ **៥៣%** នៃពិភពលោកមិនមានលទ្ធភាពក្នុងការប្រើប្រាស់អ៊ីនធឺណិតក្នុងល្បឿនលឿននោះទេ ដែលនេះបានជះផលអវិជ្ជមាននៅក្នុងលក្ខខណ្ឌនៃការរួមបញ្ចូលសេដ្ឋកិច្ច សង្គម នយោបាយ និងសមភាព។ ទោះជាយ៉ាងណាក៏ដោយ យើងឃើញមានកិច្ចខិតខំប្រឹងប្រែងជាច្រើន ដោយរដ្ឋាភិបាល និងភាគីពាក់ព័ន្ធនានា ដើម្បីដោះស្រាយលើបញ្ហាគម្លាតឌីជីថល តាមរយៈគំនិតផ្តួចផ្តើមលើការឧបត្ថម្ភធនធានសម្រាប់ការចូលប្រើប្រាស់អ៊ីនធឺណិត, កម្មវិធីអក្ខរកម្មឌីជីថលដែលដឹកនាំដោយសហគមន៍ និងសកម្មភាពនានាជាច្រើនផ្សេងៗទៀត។ ការប្តេជ្ញាចិត្ត និងសកម្មភាពសហការពីរដ្ឋាភិបាល និងភាគីពាក់ព័ន្ធទាំងអស់ពិតជាមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាទាំងនេះ និងដើម្បីធានាឱ្យបានថាបុគ្គលទាំងអស់មានសិទ្ធិទទួលបានឱកាសស្មើគ្នានៅក្នុងយុគសម័យឌីជីថល។

គិតមកដល់បច្ចុប្បន្ននេះ គម្លាតឌីជីថល គឺជាគម្លាត ឬការបែងចែករវាងបុគ្គល គ្រួសារ តំបន់សេដ្ឋកិច្ច និងភូមិសាស្ត្រដែលមានកម្រិតសេដ្ឋកិច្ចសង្គមខុសៗគ្នា ទៅលើឱកាសរបស់ពួកគេក្នុងការទទួលបានបច្ចេកវិទ្យាព័ត៌មានវិទ្យា ដូចជា ការប្រើប្រាស់អ៊ីនធឺណិតសម្រាប់សកម្មភាពជាច្រើន។

គម្លាតឌីជីថលអាចកើតមានឡើងដោយសារតែការរួមបញ្ចូលគ្នានៃកត្តាជាច្រើន ជាក់ស្តែងទាក់ទងនឹងថ្លៃនៃឧបករណ៍ និងសេវាកម្មនានាសម្រាប់តភ្ជាប់អ៊ីនធឺណិត ដែលអាចរារាំងទៅដល់ការប្រើប្រាស់សម្រាប់អ្នកដែលមានចំណូលទាប។ បន្ថែមពីនេះ ចំណេះដឹង និងជំនាញមិនគ្រប់គ្រាន់ដើម្បីប្រើប្រាស់ឧបករណ៍ចាំបាច់ និងបច្ចេកវិទ្យា ក៏ដូចជាកង្វះហេដ្ឋារចនាសម្ព័ន្ធដែលជួយសម្រួលដល់ការអនុម័តបច្ចេកវិទ្យាព័ត៌មានវិទ្យានៅក្នុងតំបន់មួយចំនួន ក៏ជាកត្តារួមចំណែកធ្វើឱ្យកើតមានគម្លាតឌីជីថលផងដែរ។

## I. ប្រភេទនៃគម្លាតឌីជីថល

គម្លាតឌីជីថលត្រូវបានគេបែងចែកជាប្រភេទសំខាន់ៗមួយចំនួនដូចខាងក្រោម៖

▶ **Usage divide**៖ សំដៅទៅលើភាពខុសគ្នានៃកម្រិតជំនាញដែលបុគ្គលម្នាក់ៗមាន ដើម្បីប្រើប្រាស់បច្ចេកវិទ្យាព័ត៌មានវិទ្យា ក្នុងកម្រិតផ្ទាល់ខ្លួន ឬសម្រាប់បំពេញកិច្ចការងារ។ ជាទូទៅ គម្លាតនេះអាចកើតមានឡើងដោយសារកម្រិតនៃការអប់រំដែលបុគ្គលម្នាក់ៗទទួលបាន និងបញ្ហាអាយុផងដែរ ដោយហេតុថាមនុស្សវ័យក្មេងទទួលបានការអប់រំច្រើន ដែលធ្វើឱ្យពួកគេមានជំនាញច្រើនជាងមនុស្សចាស់ដែលពួកគាត់ទទួលបានការអប់រំតិចជាង ជាពិសេសការអប់រំទាក់ទងនឹងបច្ចេកវិទ្យា។

▶ **Access divide**៖ សំដៅទៅលើវិសមភាពសេដ្ឋកិច្ច សង្គមក្នុងចំណោមបុគ្គល និងតំបន់ផ្សេងៗគ្នាដែលធ្វើឱ្យលទ្ធភាពរបស់ពួកគេក្នុងការទិញឧបករណ៍ឌីជីថល និងកម្រិតនៃការប្រើប្រាស់អ៊ីនធឺណិតមានភាពខុសគ្នា។ នៅក្នុងប្រទេសមួយចំនួន ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ លទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា ឬអ៊ីនធឺណិត និងការមានជំនាញចាំបាច់ ដើម្បីប្រើប្រាស់បច្ចេកវិទ្យាឱ្យមានប្រសិទ្ធភាព និងសុវត្ថិភាពរបស់ប្រជាជនគឺស្ថិតនៅមានកម្រិតនៅឡើយ ដែលធ្វើឱ្យកើតមានឡើងនូវគម្លាតនេះ និងតម្រូវឱ្យមានការជួយជំរុញបន្ថែមពីរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាប្រឈមនេះ។

▶ **Digital gender divide**៖ សំដៅលើភាពខុសគ្នារវាងស្ត្រី និងបុរស ទាក់ទងនឹងលទ្ធភាពរបស់ពួកគាត់ក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណិត។ ជារឿយៗក្មេងស្រី និងស្ត្រីមានលទ្ធភាពប្រើប្រាស់បច្ចេកវិទ្យា និងអ៊ីនធឺណិតតិចជាងបើធៀបនឹងក្មេងប្រុស និងបុរស។ ជាក់ស្តែង គិតត្រឹមខែមករា ឆ្នាំ២០២៣ ស្ត្រីចំនួន **៦៣,៥%** នៅលើពិភពលោកបានចូលប្រើប្រាស់អ៊ីនធឺណិត ខណៈដែលចំនួនបុរសដែលប្រើប្រាស់អ៊ីនធឺណិតមានចំនួន **៦៨,៨%**។ លើសពីនេះទៀត ការចូលរួមរបស់ស្ត្រីក្នុងការទទួលបានការអប់រំទាក់ទងនឹងជំនាញឌីជីថលក៏ស្ថិតនៅមានកម្រិតផងដែរ ដែលទាំងអស់នេះធ្វើឱ្យមានគម្លាតនេះកើតឡើង។

▶ **Quality of use divide**៖ សំដៅទៅលើវិធីផ្សេងគ្នាដែលមនុស្សប្រើប្រាស់អ៊ីនធឺណិត ហើយទទួលបានព័ត៌មានដែលពួកគេត្រូវការពីអ៊ីនធឺណិតច្រើនជាងអ្នកដទៃ ដែលមានន័យថា បើទោះបីជាមនុស្សពីរនាក់ចំណាយពេលដូចគ្នាក្នុងការស្រាវជ្រាវអ្វីមួយនៅលើអ៊ីនធឺណិតក៏ដោយ ប៉ុន្តែមិនមានន័យថាពួកគេទទួលបានព័ត៌មានដែលពួកគេត្រូវការដូចគ្នានោះទេ ហើយវិធីផ្សេងគ្នាដែលពួកគេប្រើអ៊ីនធឺណិតនឹងជះឥទ្ធិពលដល់គុណភាពនៃការប្រើប្រាស់របស់ពួកគេផងដែរ។

## II. កត្តាសំខាន់ៗអ្វីខ្លះដែលជំរុញឱ្យមានការកើតឡើងនូវគម្លាតឌីជីថល

▶ **កម្រិតនៃអក្ខរកម្មឌីជីថល៖** យោងតាមការសិក្សារបស់សហភាពអ៊ឺរ៉ុប កាលពីឆ្នាំ២០២១ បានបង្ហាញថា កម្រិតនៃអក្ខរកម្មឌីជីថលនៅក្នុងសកលលោក គឺស្ថិតនៅក្នុងកម្រិតទាបនៅឡើយ ដោយមនុស្សពេញវ័យ និងកុមារប្រមាណជា **៧៧៣លាននាក់** ពុំមានចំណេះដឹងអក្ខរកម្មឌីជីថលកម្រិតមូលដ្ឋាននៅឡើយ ដែលនេះបង្ហាញថា អក្ខរកម្មឌីជីថលមានកម្រិតទាបគឺជាចំណុចសំខាន់មួយ ដែលរុញច្រានឱ្យមាននូវគម្លាតឌីជីថលនៅក្នុងសង្គម។ ជាការពិតណាស់ អក្ខរកម្មឌីជីថលពិតជាមានសារៈសំខាន់ណាស់ក្នុងការកាត់បន្ថយគម្លាតឌីជីថល ដោយកាលដែលមានចំណេះដឹងផ្នែកអក្ខរកម្មឌីជីថលជួយជំរុញការចាប់យក ក៏ដូចជាការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលឱ្យមានសុវត្ថិភាព, ចេះស្វែងរកព័ត៌មានដែលត្រឹមត្រូវ, ចេះចែករំលែកនិងប្រើប្រាស់ព័ត៌មានតាមអនឡាញ, យល់ដឹងពីសុវត្ថិភាពនៃការប្រើប្រាស់បច្ចេកវិទ្យា និងចេះបង្កើតមាតិកាឌីជីថលផងដែរ។

▶ **កម្រិតចំណូលទាប៖** ទោះបីជា ការប្រើប្រាស់បច្ចេកវិទ្យាមានភាពទូលំទូលាយយ៉ាងណាក៏ដោយ ប៉ុន្តែតម្លៃនៃបច្ចេកវិទ្យាទាំងនោះនៅតែបន្តជាឧបសគ្គសម្រាប់ក្រុមគ្រួសារដែលមានចំណូលកម្រិតទាប ដែលជាហេតុធ្វើឱ្យការចាប់យក និងការប្រើប្រាស់បច្ចេកវិទ្យារបស់ពួកគេនៅមានកម្រិត។ បន្ថែមពីនេះ តម្លៃនៃសេវាអ៊ីនធឺណិត និង WiFi មានតម្លៃថ្លៃ ជាពិសេសសម្រាប់ប្រជាជននៅតំបន់ដាច់ស្រយាល ដោយពួកគេត្រូវចំណាយខ្ពស់ជាងប្រជាជនដែលនៅតំបន់ទីប្រជុំជន ហើយពុំសូវមានជម្រើសច្រើនក្នុងការជ្រើសរើសសេវាកម្មអ៊ីនធឺណិតក៏ដូចជាលទ្ធភាពក្នុងការទទួលបាននូវការតភ្ជាប់ដែលមានភាពរហ័សទាន់ចិត្តនោះទេ។

▶ **កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថល៖** ការសិក្សាបានបង្ហាញថា ហេដ្ឋារចនាសម្ព័ន្ធគឺជាបញ្ហាប្រឈមមួយក្នុងពេលបច្ចុប្បន្ន ដែលទាមទារឱ្យមាននូវដំណោះស្រាយ ដោយហេតុថាកាលដែលពុំមានហេដ្ឋារចនាសម្ព័ន្ធឌីជីថលគ្រប់គ្រាន់បានរួមចំណែកដល់ការជំរុញនូវគម្លាតឌីជីថលសង្គម។ នៅក្នុងគម្លាតឌីជីថល ហេដ្ឋារចនាសម្ព័ន្ធឌីជីថលចែកចេញជា ២ រួមមាន ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដែលរួមបញ្ចូលនូវអ៊ីនធឺណិត, WiFi និងសេវាទូរសព្ទជាដើម និងហេដ្ឋារចនាសម្ព័ន្ធទន់ ដែលរួមបញ្ចូលនូវលទ្ធភាពទទួលបានជំនួយផ្នែកបច្ចេកទេសនៅពេលមានបញ្ហាក៏ដូចជាការរាំងស្ទះកើតឡើង និងការបណ្ដុះបណ្ដាលលើការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ទាញយកអត្ថប្រយោជន៍ជាអតិបរិមា។ ការសិក្សារបស់ **Digital Watch Observatory** កាលពីឆ្នាំ២០២៣ បានបង្ហាញថា ប្រជាជនប្រមាណជា **៣៣%** មិនទាន់អាចធ្វើការតភ្ជាប់នូវបណ្ដាញអ៊ីនធឺណិតនៅឡើយ ជាពិសេសនៅក្នុងបណ្ដាប្រទេសកំពុងអភិវឌ្ឍន៍ និងតំបន់មួយចំនួននៃប្រទេសអភិវឌ្ឍន៍ក៏ពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការនៅឡើយផងដែរ។

▶ **Technophobia៖** នៅក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ការសិក្សាជាច្រើនបានបង្ហាញថា Technophobia បាននិងកំពុងក្លាយជាភាពរាំងស្ទះដល់ការកាត់បន្ថយគម្លាតឌីជីថលនៅក្នុងសកលលោក។ ដោយតាម

ការសិក្សារបស់ ERIC បង្ហាញថា ប្រមាណជា ៣០% នៃប្រជាជននៅក្នុងប្រទេសក្រីក្រ និងកំពុងអភិវឌ្ឍន៍មួយចំនួនមាននូវ Technophobia បើទោះបីជាពួកគាត់មានការយល់ដឹងពីអត្ថប្រយោជន៍ និងសារៈសំខាន់នៃបច្ចេកវិទ្យាយ៉ាងណាក៏ដោយ ក៏ពួកគេនៅតែមានភាពភ័យខ្លាចទៅនឹងការចាប់យកបច្ចេកវិទ្យា ដែលកើតឡើងដោយសារតែការព្រួយបារម្ភអំពីភាពស្មុគស្មាញ និងការព្រួយបារម្ភអំពីសុវត្ថិភាពការងារ ព្រមទាំងការយល់ឃើញថាបច្ចេកវិទ្យាអាចបង្កជាការរំខាន និងមានផលប៉ះពាល់ដល់ការបំពេញការងារ និងអាជីវកម្មរបស់ពួកគេ។

## III. ផលប៉ះពាល់នៃគម្លាតឌីជីថល

នាពេលបច្ចុប្បន្ន បច្ចេកវិទ្យាឌីជីថល និងការតភ្ជាប់អ៊ីនធឺណិតពិតជាមានសារៈសំខាន់ណាស់ ដោយមិនត្រឹមតែជាផ្នែកមួយដែលមិនអាចខ្វះបាននៅក្នុងការរស់នៅប្រចាំថ្ងៃរបស់មនុស្សប៉ុណ្ណោះទេ ប៉ុន្តែក៏ជាកាតាលីករដ៏សំខាន់មួយចូលរួមក្នុងការជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងប្រទេសផងដែរ។ បច្ចេកវិទ្យាឌីជីថល និងការតភ្ជាប់អ៊ីនធឺណិតបានបើកឱកាសថ្មីៗជាច្រើនដល់មនុស្សនៅលើសកលលោក ប៉ុន្តែមិនមែនមនុស្សគ្រប់គ្នាសុទ្ធតែទទួលបានឱកាស និងអាចប្រើប្រាស់ឧបករណ៍ឌីជីថល ឬអ៊ីនធឺណិតស្មើៗគ្នានោះទេ ដែលធ្វើឱ្យយើងមើលឃើញពីគម្លាតមួយដែលយើងស្គាល់ថាជា គម្លាតឌីជីថល។ គម្លាតឌីជីថលនេះអាចធ្វើឱ្យមានផលប៉ះពាល់យ៉ាងជ្រាលជ្រៅដល់សេដ្ឋកិច្ច សង្គម ហើយខាងក្រោមនេះ នឹងបង្ហាញពីផលប៉ះពាល់សំខាន់ៗមួយចំនួនដែលបណ្ដាលមកពីគម្លាតឌីជីថល៖

### ► ការរាំងស្ទះដល់ការទទួលបានការអប់រំ

នាពេលបច្ចុប្បន្ន ដើម្បីឱ្យខ្លួនអាចតាមទាន់ដំណើរបដិវត្តន៍ឧស្សាហកម្ម ៤.០ ប្រទេសជាច្រើនព្យាយាមជំរុញការធ្វើទំនើបកម្មនៅក្នុងវិស័យសេដ្ឋកិច្ចសំខាន់ៗរបស់ខ្លួន ក្នុងនោះក៏មានវិស័យអប់រំផងដែរ ដែលធ្វើឱ្យសិស្សានុសិស្សទទួលបាននូវវិធីសាស្ត្រថ្មីក្នុងការសិក្សារៀនសូត្រ ដែលបានពង្រីកវិសាលភាពនៃការរៀនសូត្ររបស់ពួកគេ ដោយពួកគេអាចរៀនបានគ្រប់ទីកន្លែងគ្រប់ពេលវេលាជាមួយឧបករណ៍វៃឆ្លាត ដែលដំណើរការដោយការតភ្ជាប់អ៊ីនធឺណិត។ ដូច្នេះ តម្រូវការសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យាទំនើប និងចំណេះដឹងផ្នែកឌីជីថលបាននិងកំពុងក្លាយជាធាតុផ្សំមួយដ៏សំខាន់សម្រាប់ការសិក្សាផ្ទាល់ និងពីចម្ងាយ។ ជាក់ស្ដែង នៅក្នុងអំឡុងពេលវិបត្តិជំងឺកូវីដ-១៩ ទាំងសិស្សានុសិស្ស និងគ្រូបង្រៀនត្រូវសិក្សា និងបង្រៀនពីចម្ងាយ ដែលនៅពេលនោះមិនត្រឹមតែជាពេលដែលបង្ហាញថាឧបករណ៍ឌីជីថល និងប្រព័ន្ធអ៊ីនធឺណិតគឺពិតជាមានភាពចាំបាច់ សម្រាប់ការសិក្សា ការបង្រៀន និងការធ្វើស្វ័យសិក្សាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាពេលដែលយើងមើលឃើញពីគម្លាតឌីជីថលបានយ៉ាងច្បាស់ផងដែរ។ សិស្សានុសិស្សដែលរស់នៅតំបន់ដាច់ស្រយាលបានជួបប្រទះបញ្ហាក្នុងការទទួលបានការអប់រំពីចម្ងាយ ដោយសារបញ្ហាប្រព័ន្ធអ៊ីនធឺណិតដំណើរការមិនទាន់រលូន, បញ្ហាជីវភាពរស់នៅ និងបញ្ហាកង្វះខាតឧបករណ៍ឌីជីថល ដែលនេះបានកាត់បន្ថយឱកាសនៅក្នុងការអភិវឌ្ឍចំណេះ និងជំនាញរបស់ពួកគេបានផងដែរ។ ផលប៉ះពាល់នៃគម្លាតឌីជីថលមិនត្រឹមតែអាចរាំងស្ទះដល់ការទទួល

បានការអប់រំទូទៅប៉ុណ្ណោះទេ ប៉ុន្តែក៏អាចរាំងស្ទះក្នុងការសិក្សាស្រាវជ្រាវពីជំនាញឌីជីថលបន្ថែមផងដែរ ដែលកង្វះជំនាញឌីជីថលនេះនឹងអាចឱ្យពួកគេជួបការលំបាកនៅក្នុងការសិក្សា និងនៅក្នុងទីផ្សារការងារដែលកំពុងមានតម្រូវការអ្នកមានជំនាញឌីជីថល ជាពិសេសធ្វើឱ្យកម្រិតនៃគម្លាតឌីជីថលកាន់តែមានការកើនឡើង។

### ការបាត់បង់ទំនាក់ទំនងសង្គម

បច្ចេកវិទ្យាព័ត៌មានវិទ្យាដើរតួនាទីយ៉ាងសំខាន់នៅក្នុងការធ្វើអន្តរកម្មសង្គមទំនើបនាពេលបច្ចុប្បន្ន ជាក់ស្តែងវត្តមាននៃថ្នាលផ្សេងៗជាច្រើន ដូចជា Facebook, Instagram និង Twitter បានផ្លាស់ប្តូរវិធីសាស្ត្រ និងជួយសម្រួលច្រើនដល់ការធ្វើ ឬភ្ជាប់ទំនាក់ទំនងរវាងមិត្តភក្តិ សមាជិកគ្រួសារ និងមនុស្សដទៃទៀតនៅក្នុងសង្គម។ បើទោះបីជា មនុស្សនៅតែអាចភ្ជាប់ទំនាក់ទំនងជាមួយអ្នកដទៃតាមរយៈការខលតាមទូរសព្ទ និងផ្ញើសារ ប៉ុន្តែបច្ចេកវិទ្យាឌីជីថលធ្វើឱ្យការទំនាក់ទំនងកាន់តែមានភាពងាយស្រួលសម្រាប់អ្នកប្រើប្រាស់ និងដើម្បីឱ្យពួកគេអាចសម្របខ្លួនទៅនឹងបរិបទថ្មីនៃការធ្វើទំនាក់ទំនងផងដែរ។ លើសពីនេះ បច្ចេកវិទ្យាទាំងនោះផ្តល់ឱ្យអ្នកប្រើប្រាស់នូវឱកាសក្នុងបង្ហាញពីគំនិត ឬក៏ទស្សនៈផ្សេងៗ និងចែករំលែកព័ត៌មាននានា ដែលធ្វើឱ្យអ្នកប្រើប្រាស់ជាច្រើនចាប់ផ្តើមពឹងផ្អែកលើបច្ចេកវិទ្យាទាំងនោះ ដើម្បីស្វែងយល់ពីព្រឹត្តិការណ៍ និងទទួលបានព័ត៌មានថ្មីៗសំខាន់ៗនៅក្នុងសង្គមផងដែរ។ ដូច្នេះ វត្តមាននៃគម្លាតឌីជីថល ឬក៏ការពុំមានលទ្ធភាពចូលប្រើប្រាស់បច្ចេកវិទ្យាឌីជីថលពេញលេញ អាចធ្វើឱ្យមនុស្សបាត់បង់ឱកាសទទួលបានអត្ថប្រយោជន៍ទាំងនេះ ជាពិសេសការធ្វើទំនាក់ទំនងជាមួយសង្គមតាមរបៀបទំនើបនាពេលបច្ចុប្បន្ន, អាចខកខាននូវព្រឹត្តិការណ៍នានា, ពុំអាចតាមទាន់នូវព័ត៌មាននិងនិន្នាការមួយចំនួនទាន់ពេលវេលា និងអាចឱ្យពួកគេមានអារម្មណ៍ថានៅដាច់ដោយឡែកពីសង្គមផងដែរ។

### ការប៉ះពាល់ដល់ឱកាសទទួលបានការងារ

នៅក្នុងសម័យកាលឌីជីថលនេះ អាជីវកម្ម និងក្រុមហ៊ុនជាច្រើនកំពុងទាញយកផលប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ដើម្បីជំរុញផលិតភាពការងារ, កាត់បន្ថយចំណាយ, ផ្តល់ជូននូវផលិតផល ឬសេវាកម្មដល់អតិថិជនបានកាន់តែល្អប្រសើរ, បន្តរក្សាភាពប្រកួតប្រជែងរបស់ខ្លួននៅក្នុងទីផ្សារ និងដើម្បីជំរុញការធ្វើបរិវត្តកម្មឌីជីថលនៅក្នុងអាជីវកម្ម និងក្រុមហ៊ុនផងដែរ។ ការណ៍នេះធ្វើឱ្យការងារកាន់តែច្រើនត្រូវការអ្នកដែលមាននូវជំនាញឌីជីថលដើម្បីបំពេញកិច្ចការទាំងនោះ ហេតុនេះធ្វើឱ្យការមានជំនាញឌីជីថលគឺជាភាពចាំបាច់ សូម្បីតែបុគ្គលិកកំពុងធ្វើការក៏ត្រូវបន្តសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍន៍ជំនាញឌីជីថលបន្ថែមផងដែរ។ ដូច្នេះ បុគ្គលដែលមិនមានជំនាញឌីជីថលអាចបាត់បង់ឱកាសទទួលបានការងារល្អៗ, លទ្ធភាពនៃការឡើងតំណែង និងទទួលបានប្រាក់បៀវត្សទាបផងដែរ បើធៀបនឹងបុគ្គលដែលមានជំនាញឌីជីថល។ លើសពីនេះ គម្លាតឌីជីថលក៏ធ្វើឱ្យបុគ្គលមួយចំនួនបាត់បង់ឱកាសក្នុងការធ្វើការងារបែប remote ឬ web-based ដែលការងារបែបនេះអាចឱ្យពួកគេរកប្រាក់ចំណូលបន្ថែមពីការងារគោលរបស់ពួកគេផងដែរ។

## ▶ ការប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច

សព្វថ្ងៃនេះ គម្លាតឌីជីថលបានក្លាយជាបញ្ហាដ៏តានតឹងមួយដែលសកលលោកកំពុងជួបប្រទះ និងកំពុងព្យាយាមដោះស្រាយ ដើម្បីកុំឱ្យបញ្ហានេះរារាំងដល់ការជំរុញការកសាងសេដ្ឋកិច្ចឌីជីថល និងការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសជាតិទាំងមូល។ គម្លាតឌីជីថលជះផលអវិជ្ជមានជារួមលើសេដ្ឋកិច្ច និងធ្វើឱ្យវិសមភាពប្រាក់ចំណូលកាន់តែស៊ីជម្រៅ។ បើប្រជាជនជាច្រើនពុំមានជំនាញឌីជីថល និងចំណេះដឹងនៃបច្ចេកវិទ្យាទំនើបទេ ពួកគេមិនអាចនឹងរីកចម្រើននៅក្នុងអាជីពរបស់ពួកគេនោះទេ ហើយការរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសនោះក៏ស្ថិតនៅកម្រិតទាបផងដែរ។ លើសពីនេះ គម្លាតឌីជីថលនេះអាចឱ្យមនុស្សស្ថិតនៅក្នុងភាពក្រីក្រ និងដាក់កម្រិតលើលទ្ធភាពដែលមនុស្សមួយចំនួនអាចរកប្រាក់ចំណូលបាន ដោយហេតុថាជាធម្មតាការងារដែលទទួលបានប្រាក់ចំណូលខ្ពស់ គឺជាការងារដែលទាមទារជំនាញឌីជីថលកម្រិតមធ្យមទៅខ្ពស់ ចំណែកឯការងារដែលទាមទារជំនាញឌីជីថលកម្រិតទាបអាចផ្តល់ប្រាក់កម្រៃតិចតួចបំផុត ដូច្នេះ ប្រសិនបើមនុស្សម្នាក់មិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត ឬខ្វះជំនាញឌីជីថលដែលចាំបាច់ក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើប ពួកគេមិនអាចទទួលបានមុខតំណែងដែលមានប្រាក់ខែខ្ពស់ទាំងនោះ និងធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចរបស់ពួកគេមិនប្រសើរឡើងនោះទេ។ ពួកគេអាចនឹងបន្តទទួលបានប្រាក់ឈ្នួលទាប ដែលមានន័យថាពួកគេបង់ពន្ធតិចដល់រដ្ឋាភិបាល ហើយអំណាចទិញរបស់ពួកគេនឹងនៅទាប ដែលធ្វើឱ្យពួកគេមិនអាចជំរុញកំណើនសេដ្ឋកិច្ចជាតិតាមរបៀបដែលបុគ្គលមានប្រាក់ចំណូលខ្ពស់អាចធ្វើបាននោះទេ ដូច្នេះប្រសិនបើចំនួនប្រជាជនរបស់ប្រទេសមួយដែលមិនមានលទ្ធភាពប្រើប្រាស់អ៊ីនធឺណិត និងជំនាញឌីជីថលមានចំនួនច្រើន គម្លាតឌីជីថលនឹងប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសនោះខ្លាំង។

## IV. វិធីសាស្ត្រសំខាន់ៗក្នុងការកាត់បន្ថយគម្លាតឌីជីថល

- **ជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថល៖** ការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថលត្រូវបានចាត់ទុកថាជាចំណុចចាប់ផ្តើម ដែលមានភាពចាំបាច់បំផុតក្នុងការកាត់បន្ថយគម្លាតឌីជីថល ដោយហេតុថាកាលដែលមាននូវចំនួនប្រជាជនកាន់តែច្រើនដែលមានលទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលនឹងរួមចំណែកធ្វើឱ្យពួកគាត់យល់ដឹងកាន់តែច្បាស់ពីសារសំខាន់ និងជួយបង្កើនសមត្ថភាពក្នុងការទាញយកអត្ថប្រយោជន៍ពីបច្ចេកវិទ្យាឌីជីថលទាំងនោះ។ យ៉ាងណាមិញ ការសិក្សាបានបង្ហាញថា តម្លៃឧបករណ៍ឌីជីថល ដូចជា ស្មាតហ្វូន, ថេបប្លេត និងកុំព្យូទ័រយួរដៃនៅតែមានតម្លៃខ្ពស់ ហើយតម្លៃនៃសេវាអ៊ីនធឺណិតនៅតែបន្តជាឧបសគ្គចម្បងមួយក្នុងការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថលនៅក្នុងសកលលោក ជាពិសេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដែលទាំងនេះបានក្លាយជាបញ្ហារាំងស្ទះដល់ការកាត់បន្ថយគម្លាតឌីជីថលក្នុងស្រុក និងសកលលោក។ ទន្ទឹមនេះ អង្គការសហប្រជាជាតិបានចាត់ទុករដ្ឋាភិបាលជាតួអង្គសំខាន់មួយក្នុងការកាត់បន្ថយគម្លាតឌីជីថលក្នុងស្រុក តាមរយៈការធ្វើឱ្យតម្លៃបច្ចេកវិទ្យា និងឧបករណ៍ឌីជីថលផ្សេងៗ, ការតភ្ជាប់អ៊ីនធឺណិត និងអគ្គិសនីមានភាពសមរម្យ ដែលអនុញ្ញាតឱ្យប្រជាជនគ្រប់រូបមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទិញយកមកប្រើប្រាស់។ បន្ថែមពីនេះ

វិស័យឯកជន និងភាគីពាក់ព័ន្ធនានាក៏ជាតួអង្គសំខាន់ ក្នុងការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថល តាមរយៈការផ្តល់ជាជំនួយ, ការចុះបញ្ជ្រាបការយល់ដឹង, ការផ្សព្វផ្សាយ, ការគាំទ្រ និងការចូលរួមជាមួយរដ្ឋាភិបាល។



**ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល៖** ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលគឺជាវិធីសាស្ត្រមួយក្នុងការដោះស្រាយគម្លាតឌីជីថល ដែលទាមទារឱ្យមានការចូលរួមពីភាគីគ្រប់ជាន់ថ្នាក់ក្នុងការរួមចំណែកអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធឌីជីថល តាមរយៈការវិនិយោគលើប្រព័ន្ធទូរគមនាគមន៍ក្នុងស្រុក ការដាក់ពង្រាយនូវឧបករណ៍ និងប្រព័ន្ធឌីជីថល ដែលត្រូវបានចាត់ទុកថារួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញការតភ្ជាប់ក្នុងស្រុក និងជំរុញបរិវត្តកម្មឌីជីថលផងដែរ។ ក្នុងនោះ ហេដ្ឋារចនាសម្ព័ន្ធឌីជីថលសំខាន់ៗរួមមាន បណ្តាញអ៊ីនធឺណិតល្បឿនលឿន, ប្រព័ន្ធខ្សែកាបអុបទិក, មជ្ឈមណ្ឌលទិន្នន័យ និងបណ្តាញ 5G ជាដើម។ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលទាំងនេះរួមចំណែកក្នុងការជំរុញប្រសិទ្ធភាពនៃការអនុវត្តការងារទាំងក្នុងវិស័យរដ្ឋ និងឯកជន, ងាយក្នុងការសម្របទៅតាមបរិបទថ្មីៗនៃបច្ចេកវិទ្យា, ជំរុញប្រសិទ្ធភាពបច្ចេកវិទ្យាដែលមានស្រាប់, អនុញ្ញាតនូវមុខងារថ្មីៗនៃបច្ចេកវិទ្យា និងធានាឱ្យបាននូវវិសាលភាពនៃសេវាទូរសព្ទ និងបណ្តាញអ៊ីនធឺណិតទាំងនៅទីប្រជុំជន និងតំបន់ដាច់ស្រយាល ដែលរួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយគម្លាតឌីជីថល។



**ការជំរុញនូវអក្ខរកម្មឌីជីថល៖** ការសិក្សាស្រាវជ្រាវជាច្រើនបានបង្ហាញអំពីសារៈសំខាន់នៃការជំរុញនូវអក្ខរកម្មឌីជីថលក្នុងស្រុក និងបានធ្វើការចាត់ទុកថា អក្ខរកម្មឌីជីថល គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពមួយក្នុងការកាត់បន្ថយគម្លាតឌីជីថលនៅទូទាំងសកលលោក។ យោងតាមអង្គការ UNESCO បានធ្វើការកំណត់ថា «អក្ខរកម្មឌីជីថល» គឺជាសកម្មភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យា និងឧបករណ៍ឌីជីថលដើម្បីស្វែងរក ប្រើប្រាស់ គ្រប់គ្រង វាយតម្លៃ បង្កើត និងចែករំលែកព័ត៌មាន ដោយសុវត្ថិភាព និងមានភាពត្រឹមត្រូវ ដែលទាមទារជំនាញបច្ចេកទេស និងការយល់ដឹង សំដៅធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចសង្គមកាន់តែប្រសើរ។ ក្នុងនោះ អក្ខរកម្មឌីជីថលផ្តោតសំខាន់លើ ៤ ចំណុចធំៗ រួមមាន ការចេះស្វែងរកព័ត៌មានត្រឹមត្រូវលើប្រព័ន្ធអ៊ីនធឺណិត, ចេះប្រើប្រាស់ និងចែករំលែកព័ត៌មានតាមអនឡាញ, យល់ដឹងពីសុវត្ថិភាពនៃបច្ចេកវិទ្យា និងការបង្កើតមាតិកាឌីជីថល និងការចែករំលែកប្រកបដោយក្រមសីលធម៌។ ទន្ទឹមនេះ World Bank បានធ្វើការចាត់ទុកថា កាលដែលជំរុញនូវអក្ខរកម្មឌីជីថលក្នុងស្រុករួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងមានអត្ថប្រយោជន៍សំខាន់ៗជាច្រើន ជាពិសេសធ្វើឱ្យប្រជាជនយល់ដឹងកាន់តែច្រើន និងចេះទាញយកនូវអត្ថប្រយោជន៍ពីបច្ចេកវិទ្យា និងចេះប្រើប្រាស់បច្ចេកវិទ្យាឌីជីថលជាជំនួយដល់ការបំពេញការងារ និងការធ្វើអាជីវកម្ម។ លើសពីនេះទៀត ដោយហេតុថាការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតក្នុងពេលបច្ចុប្បន្នមានការកើនឡើង ដូច្នេះកាលដែលមានចំណេះដឹងពាក់ព័ន្ធនឹងអក្ខរកម្មឌីជីថលនឹងកាត់បន្ថយការរងគ្រោះពីការបោកប្រាស់ និងការក្លែងបន្លំតាមប្រព័ន្ធអ៊ីនធឺណិតផងដែរ។



**ជំរុញការសិក្សាជំនាញឌីជីថល៖** ក្នុងពេលបច្ចុប្បន្ន ការចេះប្រើប្រាស់នូវឧបករណ៍ឌីជីថល ដូចជា ស្មាតហ្វូន ថេបប្លេត និងកុំព្យូទ័រ បានក្លាយជាជំនាញឌីជីថលកម្រិតមូលដ្ឋានដែលពុំអាចខ្វះបាន ខណៈដែរជំនាញឌីជីថលកម្រិតមធ្យម និងខ្ពស់ក៏កំពុងទទួលបានការចាប់អារម្មណ៍ និងធ្វើការចាប់យកជុំវិញសកលលោកផងដែរ។ ការសិក្សាបានបង្ហាញថា ជំនាញឌីជីថលបានរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញប្រសិទ្ធភាពនៃការបំពេញការងារ និងការធ្វើអាជីវកម្ម ព្រមទាំងរួមចំណែកក្នុងការកាត់បន្ថយគម្លាតឌីជីថល ធានាបាននូវធនធានមនុស្ស និងកម្លាំងពលកម្មពោរពេញដោយសមត្ថភាពសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។ ក្នុងពេលបច្ចុប្បន្ន ជំនាញឌីជីថលសំខាន់ៗមាន ដូចជា ការធ្វើទីផ្សារតាមបែបឌីជីថល, សន្តិសុខសាយប័រ, បញ្ញាសិប្បនិម្មិត, អ៊ីនធឺណិតនៃវត្ថុ, ការវិភាគទិន្នន័យ, Software Development, Mobile Development និង UX/UI Design ជាដើម ដែលជំនាញទាំងអស់នេះសុទ្ធសឹងតែជាជំនាញដែលកំពុងមានតម្រូវការខ្ពស់ និងជាជំនាញសំខាន់ ដែលរួមចំណែកក្នុងការកាត់បន្ថយគម្លាតឌីជីថលនាថ្ងៃអនាគត។



## V. អត្ថប្រយោជន៍នៃការកាត់បន្ថយគម្លាតឌីជីថល

នៅក្នុងសង្គមបច្ចុប្បន្ន បច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអប់រំ ការទំនាក់ទំនង និងការផ្តល់ឱកាសការងារ ដោយហេតុនេះ ទើបធ្វើឱ្យបច្ចេកវិទ្យាបានក្លាយជាផ្នែកមួយនៃជីវិតរស់នៅប្រចាំថ្ងៃរបស់យើង ដែលស្ទើរតែមិនអាចខ្វះបាន។ យ៉ាងណាមិញ ដោយសារតែបច្ចេកវិទ្យាកាន់តែរីកចម្រើនទៅមុខយ៉ាងឆាប់រហ័សក៏បានធ្វើឱ្យមនុស្សជាច្រើនពុំបានត្រៀមខ្លួន និងពុំអាចតាមទាន់ការវិវត្តដ៏រហ័សនេះ ដែលជាហេតុបង្កឱ្យមាននូវបញ្ហាគម្លាតឌីជីថលនៅក្នុងសង្គម។ ទន្ទឹមនេះ ដើម្បីដោះស្រាយនូវបញ្ហានេះ ស្ថាប័នរដ្ឋ ឯកជន និងគ្រប់ភាគីពាក់ព័ន្ធទាំងអស់បានព្យាយាមធ្វើសកម្មភាពជាច្រើនក្នុងការកាត់បន្ថយបញ្ហាគម្លាតឌីជីថល ដើម្បីធានាបាននូវអត្ថប្រយោជន៍ជូនបុគ្គល សហគមន៍ និងសង្គមទាំងមូល។ ការកាត់បន្ថយគម្លាតឌីជីថលផ្តល់នូវអត្ថប្រយោជន៍សំខាន់ៗជាច្រើន រួមមាន៖

- **ការទទួលបានព័ត៌មានស្មើៗគ្នា៖** ការកាត់បន្ថយគម្លាតឌីជីថលអាចធានាបានថាមនុស្សគ្រប់គ្នាអាចមានសិទ្ធិទទួលបាន និងចូលប្រើប្រាស់ព័ត៌មានបានគ្រប់ប្រភេទដោយមិនមានការរើសអើងភេទ អាយុ ឬស្រទាប់វណ្ណៈនោះទេ។ ការណ៍នេះ អាចជួយឱ្យប្រជាពលរដ្ឋមានចំណេះដឹង និងធនធានដើម្បីកែលម្អជីវិតរបស់ពួកគេ និងធ្វើការសម្រេចចិត្តប្រកបដោយការយល់ដឹង។

- **ពង្រឹងការអប់រំ៖** កាលដែលអាចចូលប្រើប្រាស់ធនធានឌីជីថល ដូចជា វគ្គសិក្សាតាមប្រព័ន្ធអ៊ីនធឺណិត, គេហទំព័រអប់រំ និងសៀវភៅអេឡិចត្រូនិកអាចបង្កើនឱកាសអប់រំសម្រាប់បុគ្គល ឬសិស្សានុសិស្សនៅក្នុងសហគមន៍ ដើម្បីពង្រឹងចំណេះដឹង ឬជំនាញផ្សេងៗក្រៅពីជំនាញគោលរបស់ពួកគេទៀតផង ដែលនេះអាចនាំឱ្យអត្រាអក្ខរកម្ម និងលទ្ធផលអប់រំកាន់តែប្រសើរឡើង។

- **ពង្រីកឱកាសសេដ្ឋកិច្ច៖** នាពេលបច្ចុប្បន្ន ឱកាសការងារគឺមិនមានការកំណត់តែក្នុងស្រុកទៀតនោះទេ ពោលយើងអាចស្វែងរកការងារបន្ថែមនៅក្រៅប្រទេសបាន ដូច្នេះ កាលដែលអាចកាត់បន្ថយគម្លាតឌីជីថលនឹងអាចផ្តល់ឱ្យប្រជាពលរដ្ឋនូវលទ្ធភាពទទួលបានឱកាសការងារតាមប្រព័ន្ធអ៊ីនធឺណិត, បង្កើនធនធានសហគ្រិន និងវេទិកាពាណិជ្ជកម្មអេឡិចត្រូនិកជាដើម ដែលទាំងនេះអាចជួយដល់ការពង្រឹងសេដ្ឋកិច្ច ដោយបង្កើតមធ្យោបាយថ្មីសម្រាប់ការបង្កើតប្រាក់ចំណូល និងកាត់បន្ថយអត្រាគ្មានការងារធ្វើ។

- **សេវាថែទាំសុខភាព៖** បច្ចេកវិទ្យាឌីជីថលអាចធ្វើឱ្យប្រសើរឡើងនូវការចូលប្រើសេវាថែទាំសុខភាពតាមរយៈថ្នាលថែទាំសុខភាព ឬពិគ្រោះជំងឺ, telemedicine, ផតថលព័ត៌មានសុខភាព និងឧបករណ៍ត្រួតពិនិត្យពីចម្ងាយជាដើម។ ការកាត់បន្ថយគម្លាតឌីជីថលនឹងអាចធានាថាមនុស្សគ្រប់គ្នា រួមទាំងប្រជាពលរដ្ឋដែលនៅតំបន់ដាច់ស្រយាល ឬជនបទអាចទទួលបានធនធាន និងសេវាថែទាំសុខភាពសំខាន់ៗយ៉ាងងាយ។

**បរិយាបន្នសង្គម៖** ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលអាចជំរុញបរិយាបន្នសង្គមតាមរយៈការផ្តល់នូវវេទិកាសម្រាប់ការទំនាក់ទំនង ការសហការ និងការចូលរួមក្នុងសហគមន៍ជាដើម។ ការកាត់បន្ថយគម្លាតឌីជីថលនឹងជួយកាត់បន្ថយភាពឯកោរបស់បុគ្គលនៅក្នុងសង្គម និងផ្តល់នូវបទពិសោធថ្មីៗសម្រាប់ពួកគេផងដែរ។

**សេវារដ្ឋាភិបាល៖** បច្ចេកវិទ្យាឌីជីថលអាចជួយសម្រួលដល់ការចូលប្រើប្រាស់សេវារដ្ឋាភិបាលឱ្យបានកាន់តែងាយស្រួល ដែលសេវាទាំងនោះ រួមមាន ការស្នើសុំការអនុញ្ញាត ការបង់ពន្ធ និងការចូលប្រើប្រាស់កម្មវិធីសុខុមាលភាពសង្គមជាដើម ដែលនេះអាចសម្រួលដំណើរការរដ្ឋបាល និងធ្វើឱ្យសេវារបស់រដ្ឋាភិបាលកាន់តែមានប្រសិទ្ធភាព និងអាចប្រើប្រាស់បានសម្រាប់ប្រជាពលរដ្ឋទាំងអស់។

## VI. ករណីសិក្សា

### កម្ពុជា

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកគម្លាតឌីជីថលថាជាបញ្ហាចម្បងមួយ ដែលទាមទារឱ្យមាននូវដំណោះស្រាយដែលមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយគម្លាតឌីជីថលក្នុងស្រុក។ កន្លងមក រាជរដ្ឋាភិបាលបានដាក់ចេញនូវសកម្មភាពមួយចំនួន ដូចជា ការអនុវត្តគម្រោងគំរូ, ការរៀបចំថ្នាលឌីជីថលនិងឯកសារពាក់ព័ន្ធ និងការរៀបចំវគ្គបណ្តុះបណ្តាលជំនាញ និងអក្ខរកម្មឌីជីថល ព្រមទាំងបានធ្វើការសហការ និងផ្តល់ការគាំទ្រដល់ភាគីពាក់ព័ន្ធ ដូចជា អង្គការជាតិ និងអន្តរជាតិ សំដៅចូលរួមជំរុញការកាត់បន្ថយគម្លាតឌីជីថលនៅកម្ពុជា។ បន្ថែមពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវគោលនយោបាយសំខាន់ៗមួយចំនួន រួមមាន៖

### គោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១

ដោយមើលឃើញពីការប្រែប្រួលយ៉ាងរហ័សនៃភូមិសាស្ត្រនយោបាយ ក៏ដូចជាការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា និងភាពចាំបាច់ក្នុងការចាប់យកនូវកាលានុវត្តភាពពីបច្ចេកវិទ្យាផងនោះ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំនូវយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ដោយបានកំណត់យកអាទិភាពគន្លឹះចំនួន ៥ គឺ មនុស្ស, ផ្លូវ, ទឹក, ភ្លើង និងបច្ចេកវិទ្យា ជាការឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ក្នុងការសម្រេចបាននូវចក្ខុវិស័យកម្ពុជា ២០៥០។ ជាគោលដៅយុទ្ធសាស្ត្ររបស់យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ជាពិសេសនៅក្នុងបញ្ចកោណទី១ រាជរដ្ឋាភិបាលផ្តោតសំខាន់លើការអភិវឌ្ឍមូលធនមនុស្ស ជាមុំទីមួយ ដោយជាយុទ្ធសាស្ត្ររាជរដ្ឋាភិបាលផ្តោតលើការពង្រឹងគុណភាពអប់រំកម្ពុជា តាមរយៈការពង្រឹងអភិបាលកិច្ចនៃការគ្រប់គ្រងគ្រឹះស្ថានអប់រំ, ពង្រឹងគុណភាពនៃការបណ្តុះបណ្តាលគ្រប់កម្រិត, បង្កើនគុណភាពនិងការចូលរៀនជំនាញ វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈ និងគណិតវិទ្យា (STEM) និងការបង្កើនអាហារូបករណ៍សម្រាប់សិស្សនិស្សិតក្រីក្រ និងជនងាយរងគ្រោះ។ ចំពោះមុំទី២ រាជរដ្ឋាភិបាល

ផ្តោតសំខាន់លើ ការបណ្តុះជំនាញបច្ចេកទេសទាំងជំនាញរឹង និងជំនាញទន់ តាមរយៈការរៀបចំជំនាញឡើងវិញ និងបង្កើនជំនាញ (Reskilling and Upskilling), ពង្រឹងនូវអេកូឡូស៊ីអភិវឌ្ឍន៍ជំនាញ និងការរៀបចំនូវតំណទានដល់សិស្សនិស្សិត ដើម្បីលើកទឹកចិត្តដល់ការចាប់យកជំនាញបច្ចេកទេសវិជ្ជាជីវៈ ជាពិសេសជំនាញអាទិភាព។ លើសពីនេះទៀត នៅក្នុងមុំទី១ នៃបញ្ចកោណទី៥ រាជរដ្ឋាភិបាលផ្តោតសំខាន់លើ ការពង្រឹងសមត្ថភាពមន្ត្រីលើជំនាញឌីជីថល លើកកម្ពស់អក្ខរកម្មឌីជីថលក្នុងចំណោមប្រជាជនទូទៅ និងការរួមបញ្ចូលជំនាញឌីជីថលជាមូលដ្ឋាននៅក្នុងកម្មវិធីសិក្សា និងការរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថលតាមវិស័យជាដើម។

### ▶ គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥

រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកការកសាងមូលធនមនុស្សឌីជីថលថាបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការកាត់បន្ថយគម្លាតឌីជីថល និងជំរុញការអភិវឌ្ឍរដ្ឋាភិបាលឌីជីថលប្រកបដោយប្រសិទ្ធភាព គុណភាព និងបរិយាបន្ន។ នៅក្នុងយុទ្ធសាស្ត្រទី ៧ នៃ **គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥** បានដាក់ចេញនូវសកម្មភាពអាទិភាពដូចខាងក្រោម៖

- រៀបចំក្របខណ្ឌវាស់វែងកម្រិតសមត្ថភាពនិងទទួលស្គាល់ជំនាញបច្ចេកទេស និងគោលនយោបាយគ្រប់គ្រងកៀរគរ និងលើកទឹកចិត្តមូលធនមនុស្សជំនាញឌីជីថលក្នុងវិស័យសាធារណៈ ដើម្បីគាំទ្រដល់បរិវត្តកម្មឌីជីថល និងអភិវឌ្ឍរដ្ឋាភិបាលឌីជីថល
- ជំរុញការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំឌីជីថល ជាពិសេសដល់ស្ត្រីនៅតាមក្រសួងស្ថាប័ន ដើម្បីលើកកម្ពស់សមត្ថភាពអភិបាលកិច្ចឌីជីថល
- ជំរុញការបណ្តុះបណ្តាលអក្ខរកម្មឌីជីថល និងជំនាញឌីជីថលចាំបាច់នានាដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការសម្រាប់បម្រើដល់ការអភិវឌ្ឍ ការគ្រប់គ្រង ការប្រើប្រាស់ និងការផ្តល់សេវាសាធារណៈ
- ជំរុញការរៀបចំ និងកែលម្អកម្មវិធីសិក្សា ដើម្បីលើកកម្ពស់អក្ខរកម្មឌីជីថលសម្រាប់សិស្ស និស្សិត និងវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទូទៅ
- ជំរុញការធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធឌីជីថលសម្រាប់ការអប់រំ និងបណ្តុះបណ្តាល ដូចជា ការតភ្ជាប់អ៊ីនធឺណិត, បំពាក់សម្ភារៈបរិក្ខារឌីជីថល, ថ្នាលអប់រំនិងបណ្តុះបណ្តាល និងការអភិវឌ្ឍមាតិកាអប់រំឌីជីថលជាដើម ដើម្បីគាំទ្រដល់ការអប់រំ និងការបណ្តុះបណ្តាលអក្ខរកម្មឌីជីថលដល់គ្រឹះស្ថានអប់រំគ្រប់កម្រិត និងបណ្តុះបណ្តាល
- រៀបចំកម្មវិធីបណ្តុះបណ្តាល កម្មវិធីបញ្ជ្រាបការយល់ដឹង និងការអប់រំពីចំណេះដឹងមូលដ្ឋានបច្ចេកវិទ្យាឌីជីថល និងការប្រើប្រាស់សេវាសាធារណៈឌីជីថល លើកកម្ពស់អក្ខរកម្មឌីជីថលក្នុងចំណោមប្រជាពលរដ្ឋ ដោយសហការជាមួយតួអង្គពាក់ព័ន្ធ ជាពិសេសស្ថាប័នផ្សព្វផ្សាយ និងអាជ្ញាធរមូលដ្ឋាន
- ជំរុញការរៀបចំថ្នាលអប់រំ និងបណ្តុះបណ្តាលជាតិ ដើម្បីផ្តល់មាតិកាអប់រំសម្រាប់កាត់បន្ថយគម្លាតឌីជីថលក្នុងចំណោមប្រជាពលរដ្ឋ ជាពិសេសតាមតំបន់ដាច់ស្រយាលតាមរយៈប្រព័ន្ធអនឡាញ

និងជំរុញការសិក្សាពេញមួយជីវិត

- រៀបចំក្របខណ្ឌសមត្ថភាពឌីជីថលជាតិ ដែលកំណត់ស្តង់ដាគុណវុឌ្ឍិ សមត្ថភាពនិងជំនាញបច្ចេកវិទ្យាឌីជីថលសំខាន់ៗ ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍរដ្ឋាភិបាលឌីជីថល សេដ្ឋកិច្ច និងសង្គមឌីជីថល និងឧស្សាហកម្មជំនាន់ទី៤។

## ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥

ដោយមើលឃើញពីធនធានមនុស្សក្នុងស្រុកនៅមានកម្រិត ធៀបនឹងបណ្តាប្រទេសក្នុងតំបន់ ក៏ដូចជាភាពចាំបាច់ក្នុងការទាញយកអត្ថប្រយោជន៍ជាអតិបរិមាពីភាគលាភប្រជាសាស្ត្រ សំដៅចាប់យកអត្ថប្រយោជន៍ពីបរិវត្តកម្មសេដ្ឋកិច្ច និងសង្គមឌីជីថល ដែលទាមទារនូវមូលធនមនុស្សដែលពោរពេញដោយចំណេះដឹងមូលដ្ឋាន និងជំនាញឌីជីថលគ្រប់គ្រាន់ ទើបរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ **ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥** ដោយមានចក្ខុវិស័យច្បាស់លាស់មួយគឺ ការសម្រេចបាននូវចក្ខុវិស័យក្នុងការកសាងសេដ្ឋកិច្ច និងសង្គមឌីជីថលរស់រវើក តាមរយៈការរៀបចំមូលដ្ឋានគ្រឹះជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលនៅក្នុងគ្រប់តួអង្គសង្គម ទាំងរដ្ឋ ទាំងពលរដ្ឋ និងទាំងធុរជន ដើម្បីជំរុញសន្ទុះកំណើនសេដ្ឋកិច្ចថ្មី និងលើកកម្ពស់សុខុមាលភាពសង្គម តាមគន្លងប្រក្រតីភាពថ្មីដោយផ្តោតលើអាទិភាពលើមុខព្រួញជាក់លាក់ចំនួន ៣ រួមមាន **១.**ការអភិវឌ្ឍធនធានមនុស្សឱ្យមានភាពជាអ្នកដឹកនាំឌីជីថល ដែលជំរុញអ្នកដឹកនាំបង្កើនការទទួលយក និងការសម្របខ្លួនទៅនឹងការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យា ដើម្បីកសាងនូវរបៀបគ្រប់គ្រងថ្មី ផ្អែកលើមូលដ្ឋាននៃបច្ចេកវិទ្យាឌីជីថល សម្រាប់ការធ្វើអភិបាលកិច្ច ការប្រាស្រ័យទាក់ទង ការសម្រេចចិត្តឬការដោះស្រាយបញ្ហានានា, **២.**ការទាក់ទាញធនធានមនុស្សមានទេពកោសល្យឌីជីថល តាមរយៈការអប់រំបណ្តុះបណ្តាល និងការអនុវត្ត ដោយក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ រាជរដ្ឋាភិបាលបានបង្កើតនូវមូលនិធិអភិវឌ្ឍន៍ជំនាញ, មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ និងមជ្ឈមណ្ឌល ICT ជាដើម ក្នុងការកសាងនូវសមត្ថភាព និងជំនាញឌីជីថលសម្រាប់ប្រជាពលរដ្ឋ និង **៣.**ការប្រែក្លាយពលរដ្ឋកម្ពុជាឱ្យទៅជាពលរដ្ឋឌីជីថល ទាំងនៅក្នុងវិស័យសាធារណៈ និងវិស័យឯកជន និងជ្រៀតដល់កម្រិតសហគមន៍មូលដ្ឋាន តាមរយៈការពង្រឹងនូវអក្ខរកម្មឌីជីថលទាំងកម្រិតមូលដ្ឋាន និងកម្រិតខ្ពស់។

## ផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាឌីជីថល ២០២៣

ផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាឌីជីថលគឺជាឯកសារយុទ្ធសាស្ត្រដែលបង្ហាញពីចក្ខុវិស័យ គោលដៅក្នុងការអភិវឌ្ឍបច្ចេកវិទ្យាឌីជីថលក្នុងព្រះរាជាណាចក្រកម្ពុជា តាមរយៈការបង្កើនចំណេះដឹងផ្នែកឌីជីថល និងជំនាញព័ត៌មានវិទ្យា ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យឌីជីថល, ធ្វើពិពិធកម្មហេដ្ឋារចនាសម្ព័ន្ធឌីជីថលនៅក្នុងប្រព័ន្ធនវានុវត្តន៍ជាតិសម្រាប់វិស័យអាទិភាព និងការកសាងនូវប្រព័ន្ធអេកូឡូស៊ីរស់រវើក តាមរយៈការតភ្ជាប់ឌីជីថល និងរូបវន្ត។ រាជរដ្ឋាភិបាលបានកំណត់នូវយុទ្ធសាស្ត្រជាអាទិភាព រួមមាន ឧបករណ៍ឌីជីថល, ហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត,

ថ្នាលអាជីវកម្មអនឡាញ, ស្វែមឬកម្មវិធីអប់រំឌីជីថល, កម្មវិធីសម្រាប់អភិវឌ្ឍន៍ជំនាញឌីជីថលឡើងវិញ ឬបង្កើនជំនាញ, ព្រឹត្តិការណ៍នៃការយល់ដឹងជាសាធារណៈ, មជ្ឈមណ្ឌលទិន្នន័យជាតិ និងមជ្ឈមណ្ឌលឧត្តមភាព។

## តំបន់អាស៊ាន

បញ្ហាគម្លាតឌីជីថលគឺកើតឡើងនៅគ្រប់ប្រទេសលើសកលលោក ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ ដោយហេតុថាប្រទេសទាំងនោះភាគច្រើនគឺជាប្រទេសដែលទើបនឹងចាប់យកបច្ចេកវិទ្យា មានការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលតិចតួច និងការយល់ដឹងផ្នែកអក្ខរកម្មឌីជីថលនៅមានកម្រិត។ បើយើងក្រឡេកមកមើលប្រទេសនៅក្នុងតំបន់អាស៊ានវិញ គម្លាតឌីជីថលក៏ជាបញ្ហាមួយដែលត្រូវបានយកចិត្តទុកដាក់ខ្លាំងពីបណ្តាប្រទេសនៅក្នុងតំបន់ ហើយបញ្ហាធំៗចម្បងចំនួន ៣ នៅក្នុងអាស៊ាន រួមមាន ល្បឿននៃអ៊ីនធឺណិត, ការប្រើប្រាស់អ៊ីនធឺណិត និងការផលិតបច្ចេកវិទ្យា។ ទន្ទឹមនេះ រដ្ឋាភិបាលក្នុងតំបន់ និងភាគីពាក់ព័ន្ធបានធ្វើសកម្មភាព និងបានដាក់ចេញនូវយុទ្ធសាស្ត្រនយោបាយជាច្រើន ដើម្បីដោះស្រាយបញ្ហាគម្លាតឌីជីថល និងធានាឱ្យបានថាប្រទេសក្នុងតំបន់អាស៊ានអាចមានសិទ្ធិស្មើៗគ្នាក្នុងការចូលប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណិត។ ខាងក្រោមនេះជាសកម្មភាព និងការដាក់នូវយុទ្ធសាស្ត្រនយោបាយសំខាន់ៗមួយចំនួន ដែលរដ្ឋាភិបាលក្នុងតំបន់អាស៊ាន និងភាគីពាក់ព័ន្ធប្រើប្រាស់ក្នុងការកាត់បន្ថយគម្លាតឌីជីថល៖

- យោងតាមរបាយការណ៍របស់អង្គការ UNICEF យុវជនភាគច្រើននៅក្នុងអាស៊ានមានកម្រិតចំណេះដឹងផ្នែកឌីជីថលមធ្យម ប៉ុន្តែមានភាពខុសគ្នាខ្លាំងបើប្រៀបធៀបទៅនឹងប្រទេសជឿនលឿនជាក់ស្តែង ជាងពាក់កណ្តាលនៃយុវជនដែលមានអាយុពី ១០ - ២៤ ឆ្នាំ ឬ **៦១%** មិនទទួលបានការអប់រំជំនាញឌីជីថលនៅក្នុងកម្មវិធីសិក្សារបស់ពួកគេនោះទេ។ យ៉ាងណាមិញ ដើម្បីដោះស្រាយនូវបញ្ហានេះ នៅក្នុងខែតុលា ឆ្នាំ២០២០ រដ្ឋមន្ត្រីក្រសួងអប់រំអាស៊ានទាំង ១០ បានប្តេជ្ញាចិត្តក្នុងការលើកកម្ពស់អក្ខរកម្មឌីជីថល, ការអភិវឌ្ឍជំនាញដែលអាចផ្ទេរបាន និងបង្កើតលទ្ធភាពទទួលបានឱកាសសិក្សាសម្រាប់យុវជន និងកុមារទាក់ទងនឹងបច្ចេកវិទ្យាឌីជីថលប្រកបដោយសុវត្ថិភាព។ កាលដែលផ្តល់ឱ្យយុវជន និងកុមារគ្រប់រូបនូវលទ្ធភាពចូលប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាព និងការទទួលខុសត្រូវ អាចជាសមភាពដ៏មានឥទ្ធិពលមួយសម្រាប់ការអភិវឌ្ឍមូលធនមនុស្ស។ ទន្ទឹមនេះ ជាមួយនឹងការរីកលូតលាស់នៃបច្ចេកវិទ្យា និងការកើនឡើងនៃដៃគូពាក់ព័ន្ធដែលផ្តល់នូវការសិក្សាតាមប្រព័ន្ធអ៊ីនធឺណិតនឹងអាចផ្តល់ឱកាសឱ្យយុវជនអាចធ្វើការសិក្សាបានគ្រប់ទីកន្លែង និងគ្រប់ពេលវេលា។
- ***ASEAN ICT Master Plan 2020 (AIM 2020)*** ៖ ផែនការនេះបានគូសបញ្ជាក់អំពីយុទ្ធសាស្ត្រ និងសកម្មភាពនានាក្នុងការលើកកម្ពស់ការអភិវឌ្ឍ ICT និងជាស្ពានក្នុងការកាត់បន្ថយគម្លាតឌីជីថលនៅក្នុងអាស៊ាន។ AIM 2020 ផ្តោតសំខាន់លើការកែលម្អហេដ្ឋារចនាសម្ព័ន្ធ ICT, លើកកម្ពស់សមត្ថភាពមូលធនមនុស្ស, លើកកម្ពស់កម្មវិធី ICT នៅក្នុងវិស័យសំខាន់ៗ ដូចជា វិស័យអប់រំ និងសុខាភិបាល ព្រមទាំងធ្វើការជំរុញឱ្យមានគោលនយោបាយ និងបទប្បញ្ញត្តិសម្រាប់ការអភិវឌ្ឍ ICT។

▶ **ASEAN Digital Integration Framework (ADIF)៖** ADIF ផ្ដល់នូវក្របខណ្ឌយុទ្ធសាស្ត្រសម្រាប់ការរួមបញ្ចូលគំនិតផ្ដួចផ្ដើមឌីជីថលទៅកាន់សសរស្ដម្ភសេដ្ឋកិច្ច សង្គម និងការអភិវឌ្ឍរបស់អាស៊ាន។ ក្របខណ្ឌយុទ្ធសាស្ត្រនេះមានគោលបំណងទាញយកសក្ដានុពលពីបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់កំណើនរួមបញ្ចូល និងកាត់បន្ថយគម្លាតឌីជីថលនៅក្នុងតំបន់។

▶ **ការតភ្ជាប់ឌីជីថលអាស៊ាន៖** អាស៊ានបាននិងកំពុងធ្វើការតភ្ជាប់ឌីជីថលនៅក្នុងតំបន់ តាមរយៈគំនិតផ្ដួចផ្ដើម ដូចជា The ASEAN ICT Master Plan និង The ASEAN Broadband Corridor។ កិច្ចខិតខំប្រឹងប្រែងទាំងនេះផ្ដោតសំខាន់លើការស្វែងរកការកែលម្អហេដ្ឋារចនាសម្ព័ន្ធឆ្លងព្រំដែន, កាត់បន្ថយតម្លៃ Roaming និងលើកកម្ពស់ការតភ្ជាប់ Seamless ដើម្បីជួយសម្រួលដល់ការដាក់បញ្ចូលឌីជីថល និងការធ្វើសមាហរណកម្មសេដ្ឋកិច្ច។

▶ **ការកសាងសមត្ថភាព និងការអភិវឌ្ឍជំនាញ៖** អាស៊ានបានផ្ដល់អាទិភាពដល់គំនិតផ្ដួចផ្ដើមនានាដើម្បីបង្កើនចំណេះដឹងផ្នែកឌីជីថល និងការអភិវឌ្ឍជំនាញសម្រាប់ប្រជាជនរបស់ខ្លួន។ ទាំងនេះរួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់ការអប់រំ STEM ផ្ដល់ការបណ្ដុះបណ្ដាលជំនាញឌីជីថល និងភាពជាសហគ្រិន និងគាំទ្រគំនិតផ្ដួចផ្ដើមដែលផ្ដល់អាទិភាពដល់ប្រភេទក្រុមដែលងាយរងគ្រោះ រួមទាំងស្ត្រី និងយុវជន ដើម្បីអាចឱ្យពួកគេមានឱកាសចូលរួមនៅក្នុងសេដ្ឋកិច្ចសង្គមឌីជីថល។

▶ **ការដាក់បញ្ចូលឌីជីថលសម្រាប់សហគមន៍ដែលងាយរងគ្រោះ៖** អាស៊ានបានទទួលស្គាល់អំពីសារៈសំខាន់នៃការធានាការអភិវឌ្ឍឌីជីថលដែលផ្ដល់នូវអត្ថប្រយោជន៍ដល់គ្រប់ផ្នែកទាំងអស់នៃសង្គម រួមទាំងសហគមន៍ដែលងាយរងគ្រោះ ដូចជា ប្រជាជននៅទីជនបទ ជនជាតិដើមភាគតិច និងជនពិការជាដើម។ ថ្នាក់ដឹកនាំអាស៊ានបានខិតខំប្រឹងប្រែងធ្វើការដោះស្រាយនូវបញ្ហាជាច្រើនក្នុងការដាក់បញ្ចូលបច្ចេកវិទ្យាឌីជីថល ដូចជា ការដោះស្រាយលើបញ្ហាការចូលប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធនៅមានកម្រិត និងកង្វះចំណេះដឹងផ្នែកឌីជីថលជាដើម។

▶ **សុវត្ថិភាពតាមប្រព័ន្ធអ៊ីនធឺណិត និងការការពារទិន្នន័យ៖** អាស៊ានបាននិងកំពុងធ្វើការពង្រឹងលើក្របខណ្ឌការពារសុវត្ថិភាពអ៊ីនធឺណិត និងទិន្នន័យ ដើម្បីកសាងទំនុកចិត្ត និងភាពជឿជាក់លើបច្ចេកវិទ្យាឌីជីថល។ ការពង្រឹងនេះរួមបញ្ចូលទាំងកិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យស្តង់ដាសន្តិសុខតាមប្រព័ន្ធអ៊ីនធឺណិតមានភាពស៊ីចង្វាក់គ្នា, បង្កើនកិច្ចសហប្រតិបត្តិការលើការកសាងសមត្ថភាពសន្តិសុខអ៊ីនធឺណិត និងលើកកម្ពស់ការយល់ដឹងអំពីការអនុវត្តល្អៗនៃសុវត្ថិភាពអ៊ីនធឺណិតក្នុងចំណោមរដ្ឋសមាជិកអាស៊ាន។

▶ **Public-Private Partnerships (PPPs)៖** PPPs សំដៅដល់ការផ្ដោតសំខាន់លើ កិច្ចសហការរវាងរដ្ឋាភិបាល អង្គភាពវិស័យឯកជន និងអង្គការសង្គមស៊ីវិលក្នុងការលើកកម្ពស់ការដាក់បញ្ចូលបច្ចេកវិទ្យាឌីជីថល។ PPPs ដើរតួនាទីយ៉ាងសំខាន់ក្នុងការទាញយកធនធាន, ជំនាញ និងការច្នៃប្រឌិតដើម្បីដោះស្រាយបញ្ហាគម្លាតឌីជីថល និងបង្កើនឥទ្ធិពលនៃគំនិតផ្ដួចផ្ដើមអភិវឌ្ឍន៍ឌីជីថល។

▶ ***The Master Plan on ASEAN Connectivity 2025 (MPAC)***៖ បង្កើតឡើងក្នុងគោលបំណងដើម្បីជំរុញការអនុម័តបច្ចេកវិទ្យាឌីជីថល ដោយសហគ្រាសខ្នាតតូច និងមធ្យម (MSMEs) តាមរយៈការបង្កើតផែនការការងារ ដើម្បីបង្កើនការចូលរួមរបស់ពួកគេនៅក្នុងសេដ្ឋកិច្ច សង្គមឌីជីថល។ MPAC 2025 ធ្វើការកែលម្អការប្រើប្រាស់ទិន្នន័យបើកចំហ និងការគ្រប់គ្រងទិន្នន័យឌីជីថល ដោយបង្កើតបណ្ដាញទិន្នន័យបើកចំហអាស៊ាន និងក្របខណ្ឌអភិបាលកិច្ចទិន្នន័យឌីជីថលអាស៊ាន។ បណ្ដាញទិន្នន័យបើកចំហរបស់អាស៊ានអនុញ្ញាតឱ្យប្រជាជន និងរដ្ឋាភិបាលអាចធ្វើការសហការគ្នា ដើម្បីការសម្រេចចិត្តប្រកបដោយការយល់ដឹងឆ្ពោះទៅរកការធ្វើឱ្យប្រសើរឡើងនូវការផ្ដល់សេវាសាធារណៈ។ ទន្ទឹមនេះ ក្របខណ្ឌអភិបាលកិច្ចទិន្នន័យឌីជីថលអាស៊ានក៏ផ្ដោតសំខាន់លើការជំរុញកិច្ចសហប្រតិបត្តិការក្នុងចំណោមរដ្ឋសមាជិកអាស៊ានឱ្យឆ្ពោះទៅរកការការពារទិន្នន័យផ្ទាល់ខ្លួននៅក្នុងអាស៊ានផងដែរ។

## VII. សេចក្ដីសន្និដ្ឋាន

ការកើនឡើងយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថលបានបង្កើតនូវបញ្ហាប្រឈមមួយចំនួនដែលក្នុងនោះបញ្ហាគម្លាតឌីជីថលគឺជាបញ្ហាចម្បងមួយដែលបង្កជាកង្វល់ និងបានជះផលអវិជ្ជមាននៅក្នុងលក្ខខណ្ឌនៃការរួមបញ្ចូលសេដ្ឋកិច្ច សង្គម នយោបាយ និងសមភាពទៅដល់ប្រទេសនៅលើសកលលោក។ គិតមកដល់បច្ចុប្បន្ននេះ គម្លាតឌីជីថល គឺជាគម្លាត ឬការបែងចែករវាងបុគ្គល គ្រួសារ តំបន់សេដ្ឋកិច្ច និងភូមិសាស្ត្រដែលមានកម្រិតសេដ្ឋកិច្ចសង្គមខុសៗគ្នា ទៅលើឱកាសរបស់ពួកគេក្នុងការទទួលបានបច្ចេកវិទ្យាព័ត៌មានវិទ្យា ដូចជា ការប្រើប្រាស់អ៊ីនធឺណិតសម្រាប់សកម្មភាពជាច្រើន។ បញ្ហាគម្លាតឌីជីថលអាចកើតមានឡើងបណ្ដាលមកពីកម្រិតនៃអក្ខរកម្មឌីជីថលទាប, កម្រិតចំណូលទាប, កង្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងភាពភ័យខ្លាចរបស់មនុស្សទៅនឹងការចាប់យកបច្ចេកវិទ្យាដែលទាំងអស់នេះធ្វើឱ្យគម្លាតឌីជីថលមានការកើនឡើង, រាំងស្ទះដល់ការទទួលបានការអប់រំ, ប៉ះពាល់ដល់ឱកាសទទួលបានការងារ, បាត់បង់ទំនាក់ទំនងសង្គម និងប៉ះពាល់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច ហើយដើម្បីដោះស្រាយបញ្ហាទាំងអស់នេះ ទាមទារឱ្យមានការជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថល ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ការជំរុញនូវអក្ខរកម្មឌីជីថល និងការសិក្សាជំនាញឌីជីថលបន្ថែមផងដែរ។ វិធីសាស្ត្រទាំងអស់នេះនឹងជួយកាត់បន្ថយគម្លាតឌីជីថល និងធានាថាមនុស្សទាំងអស់មានសិទ្ធទទួលបានព័ត៌មានស្មើៗគ្នា អាចពង្រីកឱកាសចូលរួមក្នុងសេដ្ឋកិច្ច ទទួលបានសេវាថែទាំសុខភាព និងសេវារដ្ឋាភិបាលល្អប្រសើរជាងមុន។ ដោយមើលឃើញពីអត្ថប្រយោជន៍ទាំងអស់នេះ បានធ្វើឱ្យប្រទេសជាច្រើនទាំងក្នុងកម្រិតសកលលោក, តំបន់ និងអាស៊ានបានយកចិត្តទុកដាក់លើបញ្ហានេះ ដោយបានដាក់ចេញនូវសកម្មភាពនានាក្នុងគោលបំណងដោះស្រាយបញ្ហានេះ ដើម្បីឱ្យការអភិវឌ្ឍសេដ្ឋកិច្ច សង្គមនៅក្នុងប្រទេសរបស់ខ្លួនកាន់តែមានការរីកចម្រើនទៅមុខទៀត។ ក្នុងនោះរដ្ឋាភិបាលកម្ពុជា និងភាគីពាក់ព័ន្ធក៏បានព្យាយាមជំរុញការចាប់យកបច្ចេកវិទ្យាឌីជីថល និងជំរុញមូលធនមនុស្សឱ្យចាប់យកជំនាញឌីជីថល តាមរយៈការដាក់ចេញនូវក្របខណ្ឌគោលនយោបាយសំខាន់ៗ ដូចជា គោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១, គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា

២០២២-២០៣៥, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងផែនទីបង្ហាញផ្លូវបច្ចេកវិទ្យាឌីជីថល៕

## ឯកសារយោង


- *Fixing the global digital divide and digital access gap*, ចេញផ្សាយថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤, https://www.brookings.edu/articles/fixing-the-global-digital-divide-and-digital-access-gap/#:~:text=While%20this%20growth%20indicates%20that,of%20compounding%20negative%20effects%20in

- *The Digital Divide: What It Is, and What's Being Done to Close It*, ចេញផ្សាយថ្ងៃទី១៨ ខែសីហា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤, https://www.investopedia.com/the-digital-divide-5116352

- *ASEAN Digital Community 2040*, ចូលអានថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤, https://www.eria.org/uploads/media/policy-brief/FY2022/ASEAN-Digital-Community-2040..pdf

- *ASEAN education ministers call for digital transformation in education*, , ចេញផ្សាយថ្ងៃទី២២ ខែតុលា ឆ្នាំ២០២០, ចូលអានថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤, https://asean.org/asean-education-ministers-call-for-digital-transformation-in-education/

- *Digital Innovation*, ចូលអានថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៤, https://connectivity.asean.org/strategic-area/digital-innovation/

- *Master Plan Oo ASEAN Connectivity 2025*, ចូលអានថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤, https://asean.org/wp-content/uploads/2016/09/Master-Plan-on-ASEAN-Connectivity-20251.pdf

- *The ASEAN ICT Masterplan 2020*, ចូលអានថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤, https://asean.org/wp-content/uploads/images/2015/November/ICT/15b%20--%20AIM%202020_Publication_Final.pdf

- *ASEAN Digital Integration Framework*, ចូលអានថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤, https://asean.org/wp-content/uploads/2020/12/Adopted-ASEAN-Digital-Integration-Framework.pdf

- *ASEAN Cybersecurity Cooperation Strategy*, ចូលអានថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៤, https://asean.org/wp-content/uploads/2022/02/01-ASEAN-Cybersecurity-Cooperation-Paper-2021-2025_final-23-0122.pdf

- *What is the digital gap?*, ចេញផ្សាយថ្ងៃទី៨ ខែមេសា ឆ្នាំ២០២២, ចូលអានថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤, https://cemeri.org/en/enciclopedia/e-que-es-brecha-digital-dv

- *Global internet usage penetration rate as of January 2024, by gender*, ចេញផ្សាយថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៤, ចូលអានថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤, https://www.statista.com/statistics/1387693/penetration-rate-of-the-internet-by-gender/#:~:text=As%20of%20January%202023%2C%20the,going%20online%20was%2068.8%20percent.

- *What Is The Digital Divide in Asia and How Is It Being Bridged?*, ចូលអានថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤, https://www.preface.ai/blog/digital-divide-asia/

- *What is the digital divide?*, ចូលអានថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤, https://www.repsol.com/en/energy-and-the-future/people/digital-divide/index.cshtml

- *The Digital Divide: What It Is, and What's Being Done to Close It*, ចេញផ្សាយថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣, ចូលអានថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៤, https://www.investopedia.com/the-digital-divide-5116352#:~:text=Understanding%20the%20Digital%20Divide,-The%20digital%20divide&text=Beyond%20the%20gaps%20between%20developed,the%20most%20visible%20digital%20divide.

- *Impact of the Digital Divide: Economic, Social, and Educational Consequences*, ចូលអានថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, https://ctu.ieee.org/impact-of-the-digital-divide-economic-social-and-educational-consequences/#:~:text=The%20digital%20divide%20has%20deepened,improve%20outcomes%20for%20all%20individuals.

- *The Global Digital Divide: Connecting a Divided World*, ចេញផ្សាយថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣, ចូលអានថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, https://robertsmith.com/global-digital-divide/

- *Economic Effects of the Digital Divide: Unlocking Growth with Equitable Access*, ចូលអានថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, https://ctu.ieee.org/economic-effects-of-the-digital-divide-unlocking-growth-with-equitable-access/#:~:text=The%20digital%20divide%20helps%20to,monthly%20costs%20of%20internet%20access.

- គោលនយោបាយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១, ចេញផ្សាយថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣,ចូលអានថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤, https://asset.cambodia.gov.kh/mptc/media/KH-PENTAGONAL-STRATEGY-PHASE-I.pdf

- *What Are the Causes of Digital Divide?* ,ចូលអាន ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ , http://www.digitalresponsibility.org/what-are-the-causes-of-digital-divide

- *Causes of the Digital Divide*,ចូលអាន ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤ , https://ctu.ieee.org/what-is-the-digital-divide/#:~:text=The%20digital%20divide%20is%20partly,and%20how%20institutions%20support%20technology.&text=Infrastructure%20is%20a%20huge%20concern,computer%20and%20an%20internet%20connection

- *International Literacy Day: narrowing the digital divide*, ចេញផ្សាយថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១, ចូលអាន ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤, https://www.eeas.europa.eu/eeas/international-literacy-day-narrowing-digital-divide_en?s=242

- *ITU report: one-third of the global population remains unconnected*, ចេញផ្សាយថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០២៣, ចូលអាន ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤, https://dig.watch/updates/itu-report-one-third-of-the-global-population-remains-unconnected

- *Digital divide persists as 22% of low-income households with children lack internet*, ចេញផ្សាយថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣, ចូលអាន ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤, https://www.k12dive.com/news/digital-divide-households-children-no-internet/694596/

- *Overcoming Resistance to Technological Change: Addressing Technophobia and Skill Gaps*, ចេញផ្សាយថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២៣, ចូលអាន ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤, https://www.linkedin.com/pulse/overcoming-resistance-technological-change-addressing-technophobia/
- *Technophobia and Technophilia among Undergraduates: Cross-national Research in Jordan, Qatar, and Egypt*, ចេញផ្សាយឆ្នាំ២០២២, ចូលអាន ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, https://files.eric.ed.gov/fulltext/EJ1375664.pdf
- *Top Five Digital Divide Solutions*, ចេញផ្សាយថ្ងៃទី១៦ ខែវិច្ឆកា ឆ្នាំ២០១៨, ចូលអាន ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, http://www.digitaldividecouncil.com/top-five-digital-divide-solutions/
- *Practical Solutions for Bridging the Digital Divide*, ចេញផ្សាយថ្ងៃទី០២ ខែមីនា ឆ្នាំ២០២៣, ចូលអាន ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, https://sertifier.com/blog/solutions-for-bridging-the-digital-divide/
- *6 Ways We Can Improve the Digital Divide´s Impact on Education*, ចេញផ្សាយថ្ងៃទី០៦ ខែមករា ឆ្នាំ២០២២, ចូលអាន ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤, https://www.globalcitizen.org/en/content/digital-divide-education-impact-improve/
- *Fixing the global digital divide and digital access gap*, ចេញផ្សាយថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២២, ចូលអាន ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤, https://www.brookings.edu/articles/fixing-the-global-digital-divide-and-digital-access-gap/
- *Solutions to the Digital Divide: Moving Toward a More Equitable Future*, ចូលអាន ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៤, https://ctu.ieee.org/solutions-to-the-digital-divide-moving-toward-a-more-equitable-future/#:~:text=Affordable%2C%20Equitable%20Access,affordable%20access%20to%20the%20internet
- *Access and skills training: The actions that will help us close the digital divide effectively*, ចេញផ្សាយថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤, ចូលអាន ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៤, https://www.weforum.org/agenda/2024/01/the-action-that-needs-to-be-taken-now-to-close-the-digital-divide/

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

កម្ពុជា ៤.0 - Cambodia 4.0

www.cambodia4point0.org

cambodia_4.0

កម្ពុជា ៤.0 - Cambodia 4.0

Cambodia 4.0 Center

គាំទ្រដោយ

មូលនិធិ ស.អ.
CBRD FUND